# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីលទ្ធផលការងារ ឆ្នាំ២០១៨ និងទិសដៅសម្រាប់ការអនុវត្ត ឆ្នាំ២០១៩

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ("រ.ទ.ស.ភ") សូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបពី លទ្ធផលការងារ ឆ្នាំ២០១៨ ដែលជាលទ្ធផលទទួលបានពីការអនុវត្តជាក់ស្ដែង ១០ខែ ដើមឆ្នាំ២០១៨ និងប៉ាន់ស្មាន ២ខែ ចុងឆ្នាំ២០១៨ (មិនទាន់ធ្វើសវនកម្ម) និងទិសដៅសម្រាប់ការអនុវត្តឆ្នាំ២០១៩ ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

**១. លទ្ធផលការងារ ឆ្នាំ២០១៨**

- ចំនួននិយោជិតសរុប ១.០៣២នាក់ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨)
- ផលិតទឹកស្អាតចំនួន ២០៧.៧៨៧.៩៤៩ ម$^{៣}$
- ការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមនថ្មី ដែលមានសមត្ថភាពផលិត ៥២.០០០ម$^{៣}$/ថ្ងៃ និងសាងសង់ដោយក្រុមហ៊ុន Vinci Construction Grands Projets អនុវត្តបានប្រមាណ ៥៣% នៃគម្រោងសាងសង់ទាំងមូល។
- ពង្រីកបណ្ដាញចែកចាយប្រវែង ២៥២.៥២៩ ម៉ែត្រ
- អត្រាទឹកគ្មានចំណូល ៨,៣៨%
- តបណ្ដាញទឹកថ្មីជូនអតិថិជនចំនួន ២៥.០១០ បណ្ដាញ
- តបណ្ដាញទឹកថ្មីជូនអតិថិជនមានចំណូលទាបចំនួន ៦០០ បណ្ដាញ
- ធ្វើការផ្សព្វផ្សាយអំពីការផលិតទឹកស្អាតប្រកបដោយគុណភាព និងគោលការណ៍ផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយ។
- ការចូលរួមយ៉ាងសកម្មក្នុងការងារសង្គម ដោយរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកនៅតាមព្រំដែន ការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម ការឧបត្ថម្ភសិស្សមកពីគ្រួសារដែលមានចំណូលទាប ក៏ដូចជាការឧបត្ថម្ភបណ្ដាញទឹកស្អាតដល់ប្រជាពលរដ្ឋមានចំណូលទាប។
- ចំណូលសរុបចំនួន ២៤៨.៣៧៣ លានរៀល

**២. ទិសដៅសម្រាប់ការអនុវត្ត ឆ្នាំ២០១៩**

| | |
|---|---|
| ▪ ផលិតទឹកស្អាតចំនួន | ២១៣.៨៩០.៨០០ ម$^{៣}$ |
| ▪ ពង្រីកបណ្ដាញចែកចាយប្រវែង | ២៥០.០០០ ម៉ែត្រ |
| ▪ តបណ្ដាញទឹកថ្មីជូនអតិថិជនចំនួន | ២២.០០០ បណ្ដាញ |
| ▪ គម្រោងចំណូលសរុបចំនួន | ២៤៦.៥៩៣.៣៧៤.០០០ រៀល |
| ▪ គម្រោងចំណាយសរុបចំនួន | ១៩២.៧៧៩.៩៨១.០០០ រៀល |
| ▪ គម្រោងចំណេញមុនបង់ពន្ធចំនួន | ៥៣.៨១៣.៣៩៣.០០០ រៀល |
| ▪ គម្រោងចំណេញពិតចំនួន | ៤៣.០៥០.៧១៤.០០០ រៀល |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៩កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

អគារ ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣- ៧២៤ ០៤៦ / (២៣) ៦៣៥ ៥០ ៨០ Email: admin@ppwsa.com.kh